01740087

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)

# គម្រោងបញ្ចប់ផែនការ

# កំណែលើកទី ២០

# ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩


**សេចក្តីសង្ខេប** ..... 3

I. **សេចក្តីផ្តើម** ..... 4

II. **វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស** ..... 10

III. **ផែនការបញ្ចប់ការស៊ើបអង្កេត** ..... 12

ក. ការិយាល័យសហចៅក្រមស៊ើបអង្កេត ..... 12

ខ. អង្គបុរេជំនុំជម្រះ ..... 13

IV. **ផែនការបញ្ចប់សវនាការ** ..... 15

ក. សំណុំរឿង០០២/០២ ..... 16

ខ. សំណុំរឿង០០៣ សំណុំរឿង០០៤/០២ និង សំណុំរឿង០០៤ ..... 18

V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ** ..... 18

ក. សំណុំរឿង០០២/០២ ..... 18

ខ. សំណុំរឿង០០៣ សំណុំរឿង០០៤/០២ និងសំណុំរឿង០០៤ ..... **Error! Bookmark not defined.**

VI. **សេចក្តីសន្និដ្ឋាន** ..... 19


ឧបសម្ព័ន្ធ ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ។

**សំគាល់៖**

គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានកែសម្រួលរៀងរាល់មួយត្រីមាសម្តង ក្នុងគោលបំណងរៀបចំផែនការ។ មាតិកានៃគម្រោងនេះរួមមានការប៉ាន់ប្រមាណនូវពេលវេលាសម្រាប់សំណុំរឿងដែលនៅសេសសល់នៃ អ.វ.ត.ក. គិតត្រឹមពេលនៃការកែសម្រួលនេះ។ កត្តាមួយចំនួន ក្នុងនោះរួមមានការវិវត្តនៃដំណើរការនីតិវិធី គឺអាចមានឥទ្ធិពលទៅលើការប៉ាន់ប្រមាណទុកទាំងនេះ។ ហេតុដូច្នេះ ពេលវេលាដែលគ្រោងទុកទាំងឡាយមិនឆ្លុះបញ្ចាំងតម្រូវការតាមផ្លូវច្បាប់ទៅលើព្រឹត្តិការណ៍សំខាន់ខុសៗគ្នានឹងត្រូវសម្រេចនៅពេលណានោះឡើយ។ គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានរៀបចំនិងចេញដោយការិយាល័យរដ្ឋបាល ដោយមានការចូលរួមយោបល់ពីការិយាល័យតុលាការទាំងអស់។

01740088

## សេចក្ដីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះ”) ត្រូវបាន រៀបចំឡើងជាលើកដំបូងនៅខែមីនា ឆ្នាំ២០១៤ ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ ការិយាល័យរដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះផ្សេងៗ សហចៅក្រមស៊ើបអង្កេត និងសហ ព្រះរាជអាជ្ញាទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាការធ្វើបច្ចុប្បន្នភាពប្រចាំត្រីមាសទី ២០ នៃគម្រោងបញ្ចប់ផែនការនេះដែលបញ្ចប់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩។

នៅក្នុងកំឡុងត្រីមាសនេះ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងអំពីសាលក្រម ក្នុងសំណុំរឿង ០០២/០២ ជាបីភាសាការងារ កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។ នៅក្នុងសំណុំរឿង ០០៣ សំណៅ បកប្រែដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ទៅជាភាសាអង់គ្លេស និងសំណៅបក ប្រែដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជាភាសាខ្មែរ ត្រូវបានជូនដំណឹង កាលពីខែកុម្ភៈ កន្លងទៅនេះ។

គម្រោងបញ្ចប់ផែនការនេះត្រូវបានធ្វើបច្ចុប្បន្នភាព ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាព នៃ ដំណើរការនីតិវិធីតុលាការគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩។

## I. សេចក្តីផ្តើម

១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អង្គជំនុំជម្រះវិសាមញ្ញ") បានចាប់ផ្តើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្តី "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩"[1]។

២ គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងបរិបទនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញឲ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ។ ឯកសារនេះធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញដោយមានការពិគ្រោះយោបល់តាមរយៈការិយាល័យរដ្ឋបាលជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អង្គជំនុំជម្រះវិសាមញ្ញ ធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី២០ ហើយបានបញ្ចូលនូវការកែតម្រូវនានា ដោយផ្អែកលើការវិវត្តនៃដំណើរការនីតិវិធីតាមផ្លូវតុលាការដែលកំពុងប្រព្រឹត្តទៅក្នុងរវាងថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩។

៣ ឯកសារនេះផ្តោតជាពិសេសលើការវិវត្តន៍នាពេលថ្មីៗនេះ នៅក្នុងសំណុំរឿងដែលនៅសេសសល់ទាំងបីដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខ អ.វ.ត.ក និងផ្តល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្តី ព្រមទាំងស្ថានភាពនៃសំណុំរឿងទាំងនោះ ព្រមទាំងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាក់ទិននឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ បញ្ចប់

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣។

ជាស្ថាពរតាមផ្លូវច្បាប់។ សហព្រះរាជអាជ្ញាបានថ្លែងជាសាធារណៈថា នឹងពុំមានសំណុំរឿងបន្ថែមទៀតទេ បន្ទាប់ពីសំណុំរឿង ០០៣ និង ០០៤[2]។ ហេតុនេះ សំណុំរឿងដែលមាននាពេលនេះគឺជាសំណុំរឿងសរុបដែល អ.វ.ត.ក. ត្រូវចាត់ការតាមនីតិវិធី។

៤ សំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេចអ៊ាវ (ហៅ ឌុច) គឺជាសំណុំរឿងដំបូងដែលជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះ អ.វ.ត.ក. ។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសសាលដីការបស់ខ្លួននៅក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ធ្វើឲ្យសំណុំរឿងនេះត្រូវបានបញ្ចប់ស្ថាពរ។ ជនជាប់ចោទត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

៥ អង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុងសំណុំរឿង ០០២ ទៅជាសវនាការតូចៗចំនួន២។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៅក្នុងសវនាការដំណាក់កាលទីមួយដែលអង្គជំនុំជម្រះវិសាមញ្ញកំណត់ឈ្មោះសំណុំរឿងថា សំណុំរឿង០០២/០១ នៅថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៤ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន។ ជនជាប់ចោទពីរនាក់ទៀតនៅក្នុងរឿងក្តី គឺ អៀង សារី ទទួលមរណភាពនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ និង អៀង ធីរិទ្ធ បានទទួលមរណភាពនៅ និងថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៥ ហេតុនេះហើយ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេត្រូវបានរំលត់។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ និងត្រូវបានផ្តន្ទាទោសម្នាក់ៗឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ទាំង នួន ជា និង ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូង។ សហព្រះរាជអាជ្ញាក៏បានដាក់បណ្តឹងសាទុក្ខកម្រិតត្រឹមតែស្នើសុំសេចក្តី

[2] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី៖ អំពីការដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីៗ ចំនួន ២ ចេញផ្សាយថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf)។ សេចក្តីថ្លែងការណ៍សាធារណៈដោយសហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ចេញផ្សាយថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf) និងសេចក្តីថ្លែងការណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងបន្ទុកការងាររបស់ អ.វ.ត.ក ចេញផ្សាយថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ (http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-eccc-caseload)។

ប្រកាសជាប្រយោជន៍ទៅលើការអនុវត្តទម្រង់ទូលាយបំផុត នៃសហឧក្រិដ្ឋកម្ម រួមដែលហៅថា JCE III ជាទម្រង់ទទួលខុសត្រូវមួយនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ ដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿងនេះត្រូវបានបញ្ចប់នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយមានការប្រកាសសាលដីកាអង្គជំនុំជម្រះតុលាការកំពូល និងបិទផ្លូវតវ៉ា។ អង្គជំនុំជម្រះតុលាការកំពូលតម្កល់សាលក្រមសាលាដំបូងដែលផ្តន្ទាទោសជនជាប់ចោទទាំងពីរដាក់ពន្ធនាគារអស់មួយជីវិត។

៦ ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែលអង្គជំនុំជម្រះវិសាមញ្ញដាក់ឈ្មោះថា សំណុំរឿង ០០២/០២ បានផ្តោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន។ បទចោទទាំងនោះរួមមាន៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើប្រធានបទ ការប្រព្រឹត្តិលើជនជាតិចាម វៀតណាម សហករណ៍ត្រាំកក់ (រួមទាំងមន្ទីរសន្តិសុខក្រាំងតាចាន់និងការប្រព្រឹទ្ធលើពុទ្ធសាសនិក) ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខអូរកន្សែង ភ្នំក្រោល និងស-២១ ការបោសសម្អាតផ្ទៃក្នុង និងការដាក់បទបញ្ជាលើអាពាហ៍ពិពាហ៍។ សវនាការលើភស្តុតាងចាប់ផ្តើមនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ហើយបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងអំពីសាលក្រមនៅក្នុងសំណុំរឿង ០០២/០២ ជាបីភាសាការងារ កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។ អង្គជំនុំជម្រះសាលាដំបូង រកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយបានផ្តន្ទាទោសជាប់ពន្ធនាគារមួយជីវិត[3]។

៧ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចបញ្ចប់កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលមានចែងនៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ដែលមិនមានបញ្ចូលនៅក្នុងសំណុំរឿង០០២/០១ ឬ០០២/០២។ ហេតុដូច្នេះ ដំណើរការនីតិវិធីតុលាការក្នុងសំណុំរឿង០០២ នឹងត្រូវបញ្ចប់នៅពេលសាលក្រមសំណុំរឿង០០២/០២ ចូលជាស្ថាពរ។

---

[3] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អសជ សាលក្រមក្នុងសំណុំរឿង០០២/០២ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ **សាធារណៈ** (https://www.eccc.gov.kh/en/document/court/case-00202-judgement)។

01740093

៨ កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ និង ០០៤ បានផ្តួចផ្តើមឡើងក្រោយពេលសហព្រះរាជអាជ្ញាអន្តរជាតិចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នៅក្នុងឆ្នាំ២០១៩ ហើយនឹងក្រោយពេលចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ ក្រោយមក សំណុំរឿង ០០៤ ត្រូវបានបំបែកចេញជាសំណុំរឿងចំនួនបីដោយឡែកពីគ្នា ពោលគឺ សំណុំរឿង ០០៤/០១ ពាក់ព័ន្ធនឹង អ៊ឹម ចែម សំណុំរឿង ០០៤/០២ ពាក់ព័ន្ធនឹង អោ អាន និងនឹងសំណុំរឿងដែលនៅសេសសល់នឹងសំណុំរឿង ០០៤ គឺពាក់ព័ន្ធនឹង យឹម ទិត្យ។

៩ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ដោយមានសម្អាងហេតុពេញលេញលើកលែងចោទប្រកាន់សំណុំរឿង ០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម។ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅមុខអង្គបុរេជំនុំជម្រះ។ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះ បានសម្រេចលើបណ្តឹងឧទ្ធរណ៍លើយុត្តាធិការបុគ្គល ក្នុងនោះរួមមាន នីតិវិធីតុលាការក្នុងសំណុំរឿងនេះផងដែរ។ សេចក្តីសម្រេចរបស់សហចៅក្រម ស៊ើបអង្កេតដែលថា អង្គជំនុំជម្រះវិសាមញ្ញមិនមានយុត្តាធិការលើ អ៊ឹម ចែម ចាត់ទុកជាបានការដែលជាការបញ្ចប់ដំណើរ ការនីតិវិធីតុលាការក្នុងសំណុំរឿងនេះ។

១០ កិច្ចស៊ើបសួរដែលកំពុងបន្តក្នុងសំណុំរឿង០០៣ ០០៤/០២ និង ០០៤ មានដូចតទៅៈ

ក- នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចំនួនពីរផ្សេងគ្នា ក្នុងសំណុំរឿង០០៣ ប្រឆាំង មាស មុត ជាភាសាធ្វើការរបស់ចៅក្រមនីមួយៗ (ខ្មែរ និងអង់គ្លេស) ដែលការបកប្រែនឹងដាក់តាមក្រោយ។ ចៅក្រមស៊ើបអង្កេតអន្តរជាតិចោទប្រកាន់ មាស មុត ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និង បទល្មើសជាតិ។ សហចៅក្រមស៊ើបអង្កេតជាតិបានទម្លាក់ការចោទប្រកាន់ដោយមូលហេតុខ្វះយុត្តាធិការបុគ្គល។ ដីកាសំណោះស្រាយទាំងពីរមានអមដោយសេចក្តីសម្រេចលើពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី។
សំណៅបកប្រែដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិជាភាសាអង់គ្លេស ត្រូវបានជូនដំណឹងនៅថ្ងៃទី១ ខែកុម្ភៈ ចំណែកសំណៅបកប្រែដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិជាភាសាខ្មែរ ត្រូវបានជូនដំណឹងនៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៩។ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ត្រូវបានដាក់ដោយសហមេធាវី មាស មុត សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញា

អន្តរជាតិបានដាក់កាលពីខែធ្នូ ឆ្នាំ២០១៨ និងកុម្ភៈ ឆ្នាំ២០១៩។ អង្គបុរេជំនុំជម្រះបានព្យាករណ៍ថានឹងអាចចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅត្រឹមត្រីមាសទី៤ ក្នុងឆ្នាំ២០១៩។

ខ- នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ចំនួនពីរផ្សេងគ្នាក្នុងសំណុំរឿង០០៤/០២ ប្រឆាំងនឹង អោ អាន ជាភាសាដែលចៅក្រមធ្វើការ (អង់គ្លេស និងខ្មែរ) ហើយការបកប្រែនឹងដាក់ជូនតាមក្រោយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចចោទប្រកាន់ អោ អាន ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទល្មើសជាតិមួយចំនួនទៀត។ សហចៅក្រមជាតិ បានទម្លាក់ការចោទប្រកាន់ដោយហេតុខ្វះយុត្តាធិការបុគ្គល។ ដីកាដំណោះស្រាយមានអមដោយសេចក្តីសម្រេចលើសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ សំណៅបកប្រែជាភាសាខ្មែរនិងអង់គ្លេសនៃដីកាដំណោះស្រាយត្រូវបានជូនដំណឹង នៅថ្ងៃ ទី៣០ ខែតុលា និងថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ ២០១៨។ សេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ ដោយសហមេធាវីការពារក្តី អោ អាន នៅខែតុលា ឆ្នាំ២០១៨ ដាក់ដោយសហព្រះរាជអាជ្ញាជាតិ និង សហព្រះរាជអាជ្ញាអន្តរជាតិ តែមួយភាសា នៅក្នុងត្រីមាសទី៤ ក្នុងឆ្នាំ២០១៨ ដោយសំណៅបកប្រែបានដាក់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩។ អង្គបុរេជំនុំជម្រះបានព្យាករណ៍ថានឹងចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅត្រឹមត្រីមាសទី៤ ក្នុងឆ្នាំ២០១៩។

គ- នៅថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧ កិច្ចស៊ើបសួរ នៅក្នុងសំណុំរឿង ០០៤ ត្រូវបានបញ្ចប់ជាលើកទី២ ក្រោយពីដោះស្រាយសំណើបន្ថែមជាច្រើនពីភាគី។ សំណុំរឿងនេះត្រូវបានបញ្ជូនទៅសហព្រះរាជអាជ្ញា ធ្វើសេចក្តីសន្និដ្ឋានស្ថាពរនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៨។ សហព្រះរាជអាជ្ញាជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨។ មេធាវីការពារក្តីបានដាក់ចម្លើយតបរួមទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញានៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ។ ដីកាដំណោះស្រាយក្នុងសំណុំរឿងនេះរំពឹងនឹងចេញត្រឹមត្រីមាសទី២ ឆ្នាំ២០១៩។ អង្គបុរេជំនុំជម្រះបានព្យាករណ៍ថានឹងចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅត្រឹមត្រីមាសទី១ ក្នុងឆ្នាំ២០២០។

១១ នៅក្នុងកំឡុងត្រីមាសនេះ ព្រឹត្តិការណ៍សំខាន់មួយត្រូវបានសម្រេច ជាមួយនឹងការជូនដំណឹងនៃសាលក្រមក្នុងសំណុំរឿង ០០២/០២ ជាបីភាសាការងារ កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។ ព្រឹត្តិការណ៍សំខាន់មួយទៀតត្រូវបានសម្រេចនៅក្នុងសំណុំរឿង ០០៣ ជាមួយនឹងការដាក់សំណៅបកប្រែដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជាភាសាខ្មែរ និងសំណៅបកប្រែដីកាដំណោះស្រាយរបស់សហចៅក្រមជាតិ ជាភាសាអង់គ្លេស កាលពីខែកុម្ភៈ ឆ្នាំ២០១៩។

១២ តាមរយៈការវិវត្តន៍ក្នុងត្រីមាសចុងក្រោយនេះ គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញកំណត់ព្រឹត្តិការណ៍សំខាន់ចំនួន៦សម្រាប់សំណុំរឿងដែលអង្គជំនុំជម្រះនានាបានទទួល។ ព្រឹត្តិការណ៍សំខាន់ដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២ និង ការព្យាករណ៍ ដែលពាក់ព័ន្ធគឺ៖

(i) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី២ ឆ្នាំ២០១៩) និង

(ii) ការចេញសាលដីកានៅក្នុងសំណុំរឿង០០២/០២ ប្រសិនបើមានបណ្តឹងសាទុក្ខ (ត្រីមាសទី៤ ឆ្នាំ២០២០)។

១៣ នៅក្នុងសំណុំរឿង ០០៣ សំណុំរឿង០០៤/០២ និងសំណុំរឿង០០៤ ព្រឹត្តិការណ៍សំខាន់ដាច់ដោយឡែកត្រូវបានកំណត់សម្រាប់ដំណាក់កាលស៊ើបសួរដែលនៅសេសសល់ហើយក្នុងករណីមានការចោទប្រកាន់នោះនឹងមានព្រឹត្តិការណ៍សំខាន់បន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះនិងបណ្តឹងសាទុក្ខ[4]។ ព្រឹត្តិការណ៍សំខាន់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលបន្តនៅសេសសល់ គឺ៖

(iii) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ណាមួយ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទី៤ ឆ្នាំ២០១៩) ។

---

[4] ដោយសារស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករចំណុចពេលវេលាជាក់លាក់ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។

(iv) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង០០៤/០២ ថាត្រូវបញ្ជូនរឿងទៅជម្រះ ឬបញ្ចប់កិច្ចដំណើរការនីតិវិធី (ត្រីមាសទី៤ ឆ្នាំ២០១៩)។

(v) ការចេញដីកាដំណោះស្រាយសំណុំរឿង០០៤ ជាមួយនឹងសេចក្តីសម្រេចថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី២ ឆ្នាំ២០១៩) និង

(vi) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី១ ឆ្នាំ២០២០)។

## II. វិធានការដែលអាចជួយបញ្ចប់កិច្ចដំណើរការនីតិវិធីបានឆាប់រហ័ស

១៤ ដំណើរការប្រកបដោយប្រសិទ្ធិភាពរបស់អង្គជំនុំជម្រះវិសាមញ្ញកន្លងទៅត្រូវបានរំខាន ដោយភាពមិននឹងនផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឲ្យបុគ្គលិកជាតិចំនួនពីររូបបានបោះបង់ការងារក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់ មហាសន្និបាតទៅលើឧបត្ថម្ភធនសម្រាប់ឆ្នាំសារពើពន្ធ២០១៤-២០១៨ សម្រាប់ភាគីអន្តរជាតិនៃ អ.វ.ត.ក គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកានិងធ្វើឲ្យមានការផ្តោតមូលទៅ លើការធ្វើឲ្យវិវត្តទៅមុខនៃអាណត្តិតុលាការ។ ចំពោះភាគីជាតិវិញ ការលំបាកផ្នែកលំហូរសាច់ប្រាក់ បាននាំឲ្យមានការពន្យារពេលបើកប្រាក់បៀវត្សសម្រាប់បុគ្គលិកជាតិនៅក្នុងកំឡុងពាក់កណ្តាល ឆ្នាំ២០១៥ ដែលប៉ះពាល់ដល់ការផ្តោតអារម្មណ៍ និងទឹកចិត្តបំពេញការងារ។

១៥ ក្រោយពីមានការសម្តែងនូវការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា មហាសន្និបាតអង្គការសហប្រជាជាតិក្នុងលក្ខណៈជាវិធានការពិសេស បានអនុញ្ញាតឲ្យអគ្គលេខាធិការសម្រេច កំណត់ទឹកប្រាក់ចំនួនមិនលើសពី ៧,៥ លានដុល្លារ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨ ដើម្បីបន្ថែមបង្គ្រប់ធនធានថវិកាស្ម័គចិត្តរបស់ភាគីអន្តរជាតិនៃ អ.វ.ត.ក សម្រាប់រយៈពេលគិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។ សកម្មភាពទាន់ពេលវេលានេះជួយសម្រួលយ៉ាងច្រើនដល់ប្រតិបត្តិការនៅ អ.វ.ត.ក មិនឲ្យរអាក់រអួលក្នុងកំឡុង៧ខែដំបូងនៃឆ្នាំ២០១៩ដោយបើកឱកាសឲ្យមានការរៃអង្គាសថវិកាស្ម័គ្រចិត្តបន្ត

ទៀត។ ជាងនេះទៀត ការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្ដល់វិភាគទានដោយផ្ទាល់ចំនួន ៣,៩ លានដុល្លារដូចដែលបានធ្វើនៅក្នុងឆ្នាំ២០១៧ ដើម្បីចំណាយទៅលើប្រាក់បៀវត្ស បុគ្គលិកជាតិ៦ ខែដំបូង ក៏ដូចជាចំណាយប្រតិបត្តិការសម្រាប់ឆ្នាំ២០១៩ គឺជាវិធានការដ៏សំខាន់ដែលជួយដល់ប្រតិបត្តិការបច្ចុប្បន្នរបស់ភាគីជាតិនៃអ.វ.ត.ក។ ដោយរួមបញ្ចូលគ្នាបែបនេះ វិធានការទាំងនេះធានាថា ទំហំការងារបច្ចុប្បន្នរបស់ អ.វ.ត.ក បានបន្តទទួលបាននូវការយកចិត្តទុកដាក់ជានិច្ច។ វិភាគទានស្ម័គ្រចិត្ត តាមការប៉ាន់ប្រមាណគឺ មានចំនួន ៦,៥ លានដុល្លារ សម្រាប់ភាគីអន្តរជាតិ។ ភាគីជាតិរំពឹងវិភាគទានពីម្ចាស់ជំនួយចំនួនមួយ។ ប៉ុន្តែ ចំនួនវិភាគទាននេះមិនទាន់បញ្ជាក់បានទេ។ ប្រការនេះផ្ទុយទៅនឹងថវិកាដែលបានអនុម័តចំនួន១៦,០១ លានដុល្លារសម្រាប់ភាគីអន្តរជាតិ និង ៥,៣៧ លានដុល្លារសម្រាប់ភាគីជាតិ។ វិភាគទានដែលបានប៉ាន់ស្មាន ទាំងនេះភាគីអន្តរជាតិបានទទួល២,៧ លានដុល្លារមកដល់ពេលនេះ។ តុល្យភាពរំពឹងនៅក្នុងឆ្នាំនេះ។

១៦ នៅខែមករា ឆ្នាំ២០១៥ កិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក បានអនុម័តវិសោធនកម្មទៅលើវិធានផ្ទៃក្នុងដែលអនុញ្ញាតឲ្យមានការកាត់បន្ថយទោលើវិសាលភាពកិច្ចស៊ើបសួរល្ហុំកណាវិសាលភាពស៊ើបអង្កេតដែលបានកាត់បន្ថយជាតំណាងឲ្យបទចោទ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យតាមការចោទប្រកាន់[5]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរពាក់ព័ន្ធនឹង មាស មុត ក្នុងសំណុំរឿង០០៣, អោ អាន ក្នុងសំណុំរឿង០០៤/០២ និង យឹម ទិត្យ ក្នុង សំណុំរឿង ០០៤ អនុលោមតាមបទបញ្ញត្តិនេះ។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិអំណាចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះក្ដីមួយដោយមិនរួមបញ្ចូលអង្គហេតុជាក់លាក់មួយចំនួនដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដរាបណាអង្គហេតុដែលនៅសល់ដែលត្រូវជម្រះ គឺជាតំណាងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជម្រះ[6]។ ឈរលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលមានចែងក្នុងសំណុំរឿង០០២ ដែលមិនមានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ ឬ០០២/០២។

---

[5] វិធាន៦៦ស្ទួន ។ សេចក្ដីសម្រេចប្រើវិធាន៦៦ស្ទួនគឺតម្រូវដោយច្បាប់ដែលនឹងធ្វើនៅដំណាក់កាលជូនដំណឹងពីការបញ្ចប់កិច្ចស៊ើបសួរ។

[6] វិធាន៨៩*ស្ទួន៣*។

១៧ ក្នុងគោលបំណងបង្កើនសមត្ថភាពស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតក្រសួងយុត្តិធម៌បានផ្តល់នីតិសម្បទាដល់មន្ត្រីច្បាប់អន្តរជាតិចំនួនប្រាំបួននាក់ ដើម្បីចុះធ្វើកំណត់ហេតុស្តាប់ចម្លើយនៅដំណាក់កាលចុះស៊ើបអង្កេតដល់មូលដ្ឋានហើយកិច្ចការនេះជាធម្មតាគឺត្រូវបំពេញដោយអ្នកស៊ើបអង្កេតប៉ុណ្ណោះ។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលលទ្ធផលពីធនធានមនុស្សរបស់ខ្លួនជាមួយនឹងបុគ្គលិកជំនាញក្រោមកម្ចីឥតសំណង និងកម្មសិក្សាការីបន្ថែមទៀតដែលបានកំណត់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានបង្កើនលទ្ធផលនៃកិច្ចស៊ើបសួរ។

១៨. ជាងនេះទៀត ការិយាល័យរដ្ឋបាលបានរក្សាសេវាកម្មរបស់បុគ្គលិកឯកទេសភាសាបន្ថែមទៀតដើម្បីគាំទ្រដល់ការិយាល័យតុលាការដើម្បីធានាសេវាបកប្រែនិងប្រតិចារឹកបានទាន់ពេលវេលា។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

១៩ ដំណាក់កាលស៊ើបអង្កេតរួមមានយុត្តាធិការរបស់ (ក) ការិយាល័យសហចៅក្រមស៊ើបអង្កេត និង (ខ) អង្គបុរេជំនុំជម្រះ នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។

២០ កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ និង ០០៤ បានផ្តួចផ្តើមឡើងក្រោយពេលសហព្រះរាជអាជ្ញាអន្តរជាតិចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នៅក្នុងឆ្នាំ២០០៩ ហើយនឹងក្រោយពេលចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ ក្រោយមក សំណុំរឿង ០០៤ ត្រូវបានបំបែកចេញជាសំណុំរឿងចំនួនបីដោយឡែកពីគ្នា ពោលគឺ សំណុំរឿង ០០៤/០១ ពាក់ព័ន្ធនឹង អ៊ឹម ចែម សំណុំរឿង ០០៤/០២ ពាក់ព័ន្ធនឹង អោ អាន និងនឹងសំណុំរឿងដែលនៅសេសសល់នឹងសំណុំរឿង ០០៤ គឺពាក់ព័ន្ធនឹង យឹម ទិត្យ។

### ក. *ការិយាល័យសហចៅក្រមស៊ើបអង្កេត*

២១ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចំនួនពីរផ្សេងគ្នាក្នុងសំណុំរឿង០០៣ ប្រឆាំងនឹង មាស មុត ជាភាសាដែលចៅក្រមធ្វើការហើយការបកប្រែនឹងដាក់ជូនតាមក្រោយ។ សំណៅបកប្រែដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិជាភាសាអង់គ្លេស ត្រូវបានជូនដំណឹងនៅថ្ងៃទី១ ខែកុម្ភៈ ចំណែកសំណៅបកប្រែដីកាដំណោះស្រាយ

របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិជាភាសាខ្មែរ ត្រូវបានជូនដំណឹងនៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៩។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចចោទប្រកាន់ មាស មុត ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទល្មើសជាតិមួយចំនួនទៀត។ សហចៅក្រមជាតិបានទម្លាក់ការចោទប្រកាន់ដោយហេតុខ្វះយុត្តាធិការបុគ្គល។

២២ ក្រោយពីចេញដីកាដំណោះស្រាយរួមមួយក្នុងសំណុំ រឿង០០៤/០១ នៅថ្ងៃ ទី១០ ខែកក្កដា ឆ្នាំ២០១៧ និងដីកាដំណោះស្រាយផ្សេងគ្នាចំនួនពីរក្នុងសំណុំ រឿង០០៤/០២ នៅថ្ងៃ ទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេត នៅសល់សំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ តែមួយគត់នៅក្រោមសមត្ថកិច្ចរបស់ខ្លួន។ ដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤ នេះ គ្រោងនឹងចេញនៅត្រីមាសទី២ ក្នុងឆ្នាំ២០១៩។

## *ខ. អង្គបុរេជំនុំជម្រះ*

២៣ ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះ បានចេញ សេចក្តីសម្រេចបន្ទាន់បង្ខំចំនួនបីទាក់ទិននឹងការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ និង០០៤/០២ និងសេចក្តីសម្រេចបន្ទាន់បង្ខំមួយ ទាក់ទិននឹងការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣។ គិតត្រឹមពេលបញ្ចប់ដំណាក់កាលធ្វើរបាយការណ៍ អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ចំនួន ៦ ប្រឆាំងនឹងដីកាដំណោះស្រាយ និងបណ្តឹងឧទ្ធរណ៍ចំនួន ២ ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ និង ០០៤/០២។

២៤ អង្គបុរេជំនុំជម្រះមានបំណងចេញសេចក្តីសម្រេចលើដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ០០៤/០២ និង០០៤ ក្នុងពេលវេលាសមស្រប អាស្រ័យលើលក្ខណៈចាប់ពីពេលទទួលដីកាសន្និដ្ឋាននានា និងការដាក់បណ្តឹងឧទ្ធរណ៍មួយចំនួន ដែលអាចប៉ាន់ស្មានថាត្រូវការចំនួន២ ត្រីមាស ក្រោយពីទទួលបានសារណា ពេញលេញលើបណ្តឹងឧទ្ធរណ៍។ ក្នុងករណីមានការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះក៏អាចត្រូវការពេលវេលាប្រមាណមួយត្រីមាស ទើបអាចចេញសេចក្តីសម្រេចទៅលើបណ្តឹងណាមួយដើម្បីសម្រេចលើបណ្តឹងទាំងអស់នោះ ក្រោយពេលចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។

២៥ ដើម្បីទទួលបានសេចក្ដីសន្និដ្ឋានពេញលេញអំពីបណ្ដឹងឧទ្ធរណ៍ សេចក្ដីសន្និដ្ឋានលើបណ្ដឹងឧទ្ធរណ៍ ចម្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានទាំងនោះ និងការឆ្លើយតបទៅនឹងចម្លើយតបទាំងនោះ ត្រូវដាក់ជាភាសាខ្មែរ និងជាភាសាអង់គ្លេស ឬ បារាំង។ នៅក្នុងសំណុំរឿង ០០៣ និង ០០៤/០២ ដីកាដំណោះស្រាយចំនួនពីរផ្ទុយគ្នា ត្រូវបានចេញក្នុងពេលដំណាលគ្នា ដោយដីកាមួយមានជាង ២៥០ ទំព័រ នៅក្នុងសំណុំរឿង ០០៣ និងដីកាមួយទៀត មាចំនួនជាង ៤០០ ទំព័រ នៅក្នុងសំណុំរឿង ០០៤/០២ តែមួយភាសាប៉ុណ្ណោះ។ ការបកប្រែដីកាទាំងនេះបានចំណាយពេលប្រហែល ០២ ខែ នៅក្នុងសំណុំរឿង ០០៣ និងជិតរយៈពេល ០៣ ខែ នៅក្នុងសំណុំរឿង ០០៤/០២ ដូច្នេះ វាបានពន្យារពេលចាប់ផ្ដើមការធ្វើសារណាលើបណ្ដឹងឧទ្ធរណ៍នៅក្នុងរឿងក្ដីទាំងនេះ។ ម្យ៉ាងវិញទៀត ដីកាដំណោះស្រាយនីមួយៗ ត្រូវបានភាគីប្ដឹងឧទ្ធរណ៍ ដែលនាំឱ្យមានបណ្ដឹងឧទ្ធរណ៍ចំនួន ០៣ ដាក់ដោយឡែកពីគ្នាប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៣ និងបណ្ដឹងឧទ្ធរណ៍ចំនួន ០៣ ដាច់ដោយឡែកពីគ្នាប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤/០២។ ដូច្នេះ ដោយសារមានការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នានៅក្នុងរឿងក្ដីទាំងនេះ ទំហំការងារនៃបណ្ដឹងឧទ្ធរណ៍មានវិសាលភាពលើសពីទ្វេដង។ លក្ខណៈពុំធ្លាប់មានពីមុនមកនៃសំណុំរឿង ០០៤/០២ បានពន្យារពេលវេលាដែលត្រូវការសម្រាប់ធ្វើសារណាលើបណ្ដឹងឧទ្ធរណ៍ឱ្យបានពេញលេញ។

២៦ ប្រសិនបើអង្គបុរេជំនុំជម្រះមានបុគ្គលិកគ្រប់គ្រាន់ ហើយប្រសិនបើការបកប្រែបានលឿនលើសេចក្ដីសន្និដ្ឋានរបស់ភាគី និងសេចក្ដីសម្រេចរបស់ចៅក្រម ទៅជាបីភាសា អ.វ.ត.ក ការប៉ាន់ស្មាននាពេលបច្ចុប្បន្ន មានដូចខាងក្រោម៖

ក. ក្នុង*សំណុំរឿង០០៤/០២* សេចក្ដីសន្និដ្ឋានលើបណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់ដោយសហមេធាវីការពារក្ដី អោ អាន សហព្រះរាជអាជ្ញាជាតិ និង សហព្រះរាជអាជ្ញាអន្តរជាតិ តែមួយភាសាតែប៉ុណ្ណោះ នៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៨ ហើយសំណៅបកប្រែត្រូវបានដាក់នៅត្រឹមថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ ចំណែកចម្លើយតបត្រូវបានសហមេធាវីការពារក្ដី អោ អាន និងសហព្រះរាជអាជ្ញាអន្តរជាតិ ដាក់តែមួយភាសា នៅត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ ជាមួយនឹងសំណៅបកប្រែបានដាក់នៅត្រឹមថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ អនុលោមតាមសេចក្ដីណែនាំរបស់អង្គជំនុំជម្រះ។ ការប៉ាន់ស្មានបច្ចុប្បន្នសម្រាប់ការបញ្ចប់សំណុំរឿង ០០៤/០២ ប្រសិនបើ*ការឆ្លើយតប*ត្រូវបានដាក់ និងបកប្រែរួចរាល់នៅត្រឹមត្រីមាសទី២ ឆ្នាំ២០១៩ អាចនឹង

មានសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចេញនៅត្រឹមត្រីមាសទី៤ ឆ្នាំ២០១៩។ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា របស់សហចៅក្រមអន្តរជាតិលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អាចនឹងរំពឹងទុកត្រឹមត្រីមាសទី១ ឆ្នាំ២០២០។

ខ. នៅក្នុង*សំណុំរឿង ០០៣* ការបកប្រែដីកាដំណោះស្រាយទាំងពីរ ត្រូវបានដាក់នៅត្រឹមថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៩។ សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ត្រូវបានសហមេធាវីការពារក្ដី មាស មុត សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ដាក់នៅក្នុងខែធ្នូ ឆ្នាំ២០១៨ និងនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៩។ ការប៉ាន់ស្មានបច្ចុប្បន្នសម្រាប់ការបញ្ចប់សំណុំរឿង ០០៣ ប្រសិនបើ*ការឆ្លើយតប*ត្រូវបានដាក់ និងបកប្រែរួចរាល់នៅត្រឹមត្រីមាសទី២ ឆ្នាំ២០១៩ អាចនឹងមានសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចេញនៅត្រឹមត្រីមាសទី៤ ឆ្នាំ២០១៩។ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមអន្តរជាតិលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អាចនឹងរំពឹងទុកត្រឹមត្រីមាសទី១ ឆ្នាំ២០២០។

គ នៅក្នុង*សំណុំរឿង ០០៤* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវបានរំពឹងថានឹងចេញនៅត្រឹមត្រីមាសទី១ ឆ្នាំ២០២០។

## IV. ផែនការបញ្ចប់សវនាការ

២៧ តារាងពេលវេលានៃការបញ្ចប់សវនាការត្រូវកំណត់ដោយកត្តានានាដូចជា៖ លក្ខណៈ និងភាពស្មុគស្មាញនៃសំណុំរឿង បញ្ហាសុខភាពរបស់ជនជាប់ចោទដែលមានវ័យចាស់ជរា ចំនួនសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ ភាពទំនេរនិងរយៈពេលនៃការធ្វើសក្ខីកម្មរបស់សាក្សីទាំងនោះ ការបង្អាក់ជាក់ស្ដែងនានាក្នុងការបំពេញកិច្ចដំណើរការនីតិវិធី ចំនួនញត្តិដាក់ដោយភាគី និងការពិនិត្យពិច័យផ្នែករដ្ឋបាលផ្សេងៗទៀត ក្នុងនោះរួមមានការបកប្រែផ្ទាល់មាត់បានត្រឹមត្រូវ និងការបកប្រែឯកសារទាន់ពេលវេលា។

២៨ ការប្រជុំរៀបចំសវនាការចំនួនមួយ ឬច្រើន តែងតែបានរៀបចំឡើងមុនពេលការចាប់ផ្តើមសវនាការជាក់ស្តែង។ សវនាការចាប់ផ្តើមដោយសវនាការបឋម។ នៅក្នុងសវនាការបឋមនេះ អង្គជំនុំជម្រះសាលាដំបូង ពិចារណាទៅលើបញ្ជីសាក្សីសក្ខីកម្មនុពល និងអ្នកជំនាញ ដែលដាក់ជូនដោយភាគី ព្រមទាំងអញ្ញត្រកម្ម លើកឡើងដោយភាគី ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តួចផ្តើមនូវចំណុចជាក់លាក់អំពីសំណងដែលខ្លួនស្នើសុំ។ សវនាការលើអង្គសេចក្តីចាប់ផ្តើមដោយមានការធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបពីសំណាក់សហព្រះរាជអាជ្ញា ហើយជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបានមុនពេលអង្គជំនុំជម្រះសាលាដំបូង ចាប់ផ្តើមតាំងសំណួរដល់ជនជាប់ចោទ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី និងស្តាប់នូវការបង្ហាញភស្តុតាង។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទអង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ក្រោយពេលពិនិត្យភស្តុតាងទាំងអស់រួច ហើយអង្គជំនុំជម្រះស្តាប់ការបិទកិច្ចពិភាក្សាដេញដោលពីសំណាក់ភាគីមុនពេលពិភាក្សាសម្រេច។ ប្រសិនបើជនជាប់ចោទត្រូវផ្តន្ទាទោស អង្គជំនុំជម្រះសម្រេចទៅលើទោសសមស្រប នៅក្នុងសាលក្រមនោះ។

## *ក. សំណុំរឿង០០២/០២*

២៩ កិច្ចដំណើរការនីតិវិធីលើភស្តុតាងបានចាប់ផ្តើមនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ដោយអង្គជំនុំជម្រះត្រូវធ្វើសវនាការចំនួន៣ថ្ងៃក្នុងមួយសប្តាហ៍។ លទ្ធផលនៃការវាយតម្លៃផ្នែកវេជ្ជសាស្ត្ររបស់ជនជាប់ចោទនៅខែមករា ឆ្នាំ២០១៥បង្ហាញថា ការកំណត់៤ថ្ងៃក្នុង១សប្តាហ៍ជាការសមស្រប ដោយសវនាការពេលព្រឹកធ្វើឲ្យបានខ្លីបន្តិច។ ដូច្នេះអង្គជំនុំជម្រះបានត្រឡប់ទៅអនុវត្តតាមពេលកំណត់៤ថ្ងៃក្នុង១សប្តាហ៍វិញ នៅខែកុម្ភៈ ឆ្នាំ២០១៥ ដែលជាការពន្លឿនដល់ការជំនុំជម្រះក្តី។ សវនាការលើភស្តុតាងបានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ ក្រោយពីពេលសវនាការអស់ចំនួន២៧៤ថ្ងៃ។ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសាក្សីសរុបចំនួន១១៤ ដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ៦៣នាក់ និង អ្នកជំនាញចំនួន៨នាក់ នៅលើប្រធានបទសហករណ៍ត្រាំកក់ (ក្នុងនោះរួមមាន មន្ទីរសន្តិសុខក្រាំងតាចាន់ និងការប្រព្រឹត្តិលើជនជាតិចាម) ការដ្ឋានទំនប់១មករា ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម និងការប្រព្រឹត្តិលើជនជាតិចាម និងជនជាតិវៀតណាម មន្ទីរសន្តិសុខអូរកន្សែង និងភ្នំក្រោល និងមន្ទីរសន្តិសុខស២១ ព្រមទាំងការបោសសម្អាតផ្ទៃក្នុង។ បទបញ្ជាឲ្យរៀបអាពាហ៍ពិពាហ៍លក្ខណៈនៃជម្លោះប្រដាប់អាវុធ និង តួនាទីរបស់ជនជាប់ចោទ។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សា

ដេញដោលបានធ្វើឡើងនៅចន្លោះថ្ងៃទី១៣ និងថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៧។ ក្រោយពេលនោះមក អង្គជំនុំជម្រះបានផ្អាកសវនាការដើម្បីពិភាក្សាសម្រេច និងរៀបចំសាលក្រមនៅក្នុងរឿងក្តីនេះ។

៣០ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមដោយផ្ទាល់មាត់ នៅក្នុងសំណុំរឿង ០០២/០២ រួមជាមួយសេចក្តីសង្ខេបនៃការរកឃើញ និងបានប្រកាសថា សាលក្រម ដែលមានសំអាងហេតុទាំងមូល នឹងចេញតាមក្រោយ។ អង្គជំនុំជម្រះបានជូនដំណឹងអំពីសាលក្រមជា បីភាសាការការនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។ អង្គជំនុំជម្រះបានរកឃើញថា នួន ជា និង ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញា ទីក្រុងហ្សឺណែវ និងបទប្រល័យពូជសាសន៍ប្រឆាំងនឹងក្រុមជនជាតិពិន្ទុ ក្រុមជាតិសាសន៍ និងក្រុម ពូជសាសន៍វៀតណាម ក្រោមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។ ទាំង នួន ជា ទាំង ខៀវ សំផន ត្រូវបានស្រេចឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ អង្គជំនុំជម្រះបានពិចារណាទោសជាប់ ពន្ធនាគារអស់មួយជីវិតដែលបានកំណត់លើ នួន ជា និង ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០១ ហើយបានស្រូបទោសនៅក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ ជាទោសជាប់ពន្ធនាគារអស់មួយ ជីវិត។

៣១ អង្គជំនុំជម្រះសាលាដំបូងនៅបន្តទទួលបន្ទុកលើសំណុំរឿងរហូតដល់ពេលមានការជូនដំណឹងអំពី បណ្តឹងសាទុក្ខ ដែលនឹងដាក់ដោយភាគីនៅចំពោះមុខអង្គជំនុំជម្រះ។ នៅពេលក្រោយពីនោះ អង្គជំនុំ ជម្រះសាលាដំបូងត្រូវបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះតុលាការកំពូលស្របតាមវិធានផ្ទៃក្នុង។

៣២ សម្បទារបស់ជនជាប់ចោទក្នុងការបន្តចូលរួមសវនាការត្រូវបានវាយតម្លៃនៅចុងខែមករា ឆ្នាំ២០១៨ ហើយពិនិត្យឃើញ ថាជន ជាប់ចោទទាំងពីរមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។ ប៉ុន្តែ របាយការណ៍វេជ្ជសាស្ត្រកត់សម្គាល់អំពីជំងឺមួយចំនួនដែលជនជាប់ចោទមាន ហើយបានផ្តល់ អនុសាសន៍ឲ្យបន្តវាយតម្លៃទៅលើមុខងារសតិបញ្ញារបស់ជនជាប់ចោទរៀងរាល់ត្រីមាស។ អង្គជំនុំ ជម្រះសាលាដំបូង បន្តពិនិត្យតាមដានស្ថានភាពសុខភាពរបស់ជនជាប់ចោទក្នុងសំណុំរឿង០០២/០២ ខណៈ ដែលខ្លួនទទួលចាត់ការសំណុំរឿងនេះ។

### ខ. *សំណុំរឿង០០៣ សំណុំរឿង០០៤/០២ និង សំណុំរឿង០០៤*

៣៣ កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ ត្រូវបានផ្តួចផ្តើមក្រោយពីដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិក្នុងឆ្នាំ២០១៩។ បន្ទាប់មក សំណុំរឿង០០៤ ត្រូវបានបំបែកជាបីសំណុំរឿង ក្នុងនោះ សំណុំរឿងចំនួន ២ ពោលគឺៈ សំណុំរឿង០០៤/២ ពាក់ព័ន្ធនឹង អោ អាន និង សំណុំរឿង០០៤ ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំងនឹង យឹម ទិត្យ ដែលនៅសេសសល់។

៣៤ រង់ចាំរហូតដល់មានសេចក្តីសម្រេចចុងក្រោយថាតើសំណុំរឿងទាំងអស់ ឬណាមួយនៃសំណុំរឿង ០០៣ សំណុំរឿង ០០៤/០២ និង សំណុំរឿង០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទើបអាចមានការប៉ាន់ប្រមាណលើពេលវេលាដែលត្រូវការដើម្បីបញ្ចប់សវនាការទាំងនេះ។ ការវាយតម្លៃទៅលើពេលវេលា ដែលត្រូវការអាចនឹងពឹងផ្អែកលើចំនួនចុងចោទនិង ភាពស្មុគស្មាញនៃច្បាប់និងអង្គហេតុនៃបទចោទក្នុងរួមមានដីកាបញ្ជូនរឿងទៅជំនុំជម្រះផង។

## V. ផែនការបញ្ចប់បណ្តឹងសាទុក្ខ

### ក. *សំណុំរឿង០០២/០២*

៣៥ អង្គជំនុំជម្រះតុលាការកំពូលព្យាករណ៍នៅពេលនេះថា រយៈពេល និង ធនធានដែលប៉ាន់ប្រមាណទុកសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០២ ពីសំណាក់ភាគីណាមួយ ដោយពុំមានព័ត៌មានផ្សេងទៀត គឺទំនងជាមានកម្រិតដូចទៅនឹងសំណុំរឿង០០២/០១ដែរ។

៣៦ ប្រសិនបើសំណុំរឿង០០៣ សំណុំរឿង០០៤/០២ សំណុំរឿង០០៤ បន្តទៅមុខរហូតដល់ដំណាក់កាលជំនុំជម្រះនោះ បណ្តឹងឧទ្ធរណ៍ភ្លាមៗ ឬបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងអាចកើតឡើង។ ទោះជាយ៉ាងណាក៏ដោយ ដោយហេតុថាយើងមិនដឹងថាសំណុំរឿងណាមួយដំណើរការរហូតដល់ដំណាក់កាលជំនុំជម្រះ និងមិនដឹងពីបទចោទណាខ្លះនោះ វាហាក់ដូចជាឆាប់ពេកក្នុងការផ្តល់នូវការប៉ាន់ស្មានចំពោះពេលវេលាដែលតម្រូវក្នុងការសម្រេចលើបណ្តឹងសាទុក្ខណានៃសំណុំរឿងពាក់ព័ន្ធ។

## VI. សេចក្តីសន្និដ្ឋាន

៣៧ ព្រឹត្តិការណ៍សំខាន់ចំនួនមួយត្រូវបានសម្រេចនៅក្នុងអំឡុងត្រីមាសនេះ ដោយមានការជូនដំណឹងអំពីសាលក្រមនៅក្នុងសំណុំរឿង ០០២/០២ ទាំងបីភាសាការងាររបស់ អ.វ.ត.ក។ ព្រឹត្តិការណ៍សំខាន់មួយទៀតត្រូវបានសម្រេចនៅក្នុងសំណុំរឿង ០០៣ ដោយមានការជូនដំណឹងអំពីការដាក់សំណៅបកប្រែជាភាសាខ្មែរនៃដីកាដំណោះស្រាយរបស់សហចៅក្រមអន្តរជាតិ និងសំណៅបកប្រែជាភាសាខ្មែរនៃដីកាដំណោះស្រាយរបស់សហចៅក្រមជាតិ។

៣៨ សម្រាប់ឆ្នាំ២០១៩ យើងរំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់ៗមួយទៀត ក្នុងសំណុំរឿង០០២/០២ គឺ (i) កាលបរិច្ឆេទសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ ព្រឹត្តិការណ៍សំខាន់ចំនួន២ក៏នឹងត្រូវបានសម្រេចគឺ (ii) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ប្រឆាំងនឹង មាស មុត ថាតើត្រូវបញ្ជូនរឿងក្តីទៅជំនុំជម្រះ ឬ បញ្ចប់កិច្ចដំណើរការនីតិវិធី និង (iii) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/០២ ប្រឆាំងនឹង អោ អាន ថាតើត្រូវបញ្ជូនរឿងក្តីទៅជំនុំជម្រះ ឬ បញ្ចប់កិច្ចដំណើរការនីតិវិធី។ ម្យ៉ាងវិញទៀត ព្រឹត្តិការសំខាន់មួយនឹងត្រូវសម្រេចដោយមាន (iv) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ទាក់ទិននឹង យឹម ទិត្យ ជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតថាត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចដំណើរការនីតិវិធី។

៣៩ សម្រាប់ឆ្នាំ២០២០ យើងរំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់២ គឺ (v) ការចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ថាតើត្រូវបញ្ជូនរឿងក្តីទៅជំនុំជម្រះ ឬ បញ្ចប់កិច្ចដំណើរការនីតិវិធី និង (vi) ការចេញសាលដីកាក្នុងសំណុំរឿង០០២/០២ ដោយអង្គជំនុំជម្រះតុលាការកំពូល។

៤០ ក្នុងករណីដែលសំណុំរឿង០០៣ សំណុំរឿង ០០៤/០២ និង សំណុំរឿង០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះទាំងមូល ឬដោយផ្នែក ពេលវេលាកំណត់សម្រាប់សំណុំរឿងទាំងនេះនឹងត្រូវព្យាករណ៍នៅពេលនោះ។

៤១ ព្រឹត្តិការណ៍សំខាន់ៗដែលបានព្យាករណ៍ មានបង្ហាញជូនក្នុងតារាងដែលភ្ជាប់ជាមួយនឹងផែនការនេះ។

# តារាងកំណត់ពេលវេលាតាមការគ្រោងទុកដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ

គម្រោងបញ្ចប់ផែនការ កំណែលើកទី ២០ - ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩




(ច) ដីកាដំណោះស្រាយដាច់ដោយឡែកតែមួយភាសា

(ឆ) ដីកាដំណោះស្រាយដាច់ដោយឡែកជាភាសាអង់គ្លេស និងភាសាខ្មែរ

(ជ) ដីកាដំណោះស្រាយ

(ឈ) សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ